# បញ្ហាប្រឈម ក្នុងការគ្រប់គ្រង ធនធានទឹករបស់ សហគមន៍កសិករប្រើប្រាស់ទឹក

*គីម ស៊ាន ស៊ូម៉ាត្រា និង ខៀវ ដារ៉ាវី រាយការណ៍ពីការវាយតំលៃខាងសង្គមកិច្ចនៃការគ្រប់គ្រងធនធានទឹកនៅតំបន់ទន្លេសាប និងពិភាក្សាពីបញ្ហាការបែងចែកទឹក ការចូលរួមរបស់ប្រជាជន ដំណើរការប្រព័ន្ធស្រោចស្រព ការថែទាំជួសជុល និងការដោះស្រាយទំនាស់ ដែលអាចជះឥទ្ធិពលដល់អភិបាលកិច្ចទឹក ។**

*កសិករម្នាក់នៅស្រុកស្រះរាំង ខេត្តបន្ទាយមានជ័យ បានលើកឡើងថាៈ "ជារៀងរាល់ឆ្នាំ ការធ្វើស្រែ គឺជាល្បែងភ្នាល់គ្នាជាមួយទឹកភ្លៀង ។ យើងមិនដឹងថានឹងបានផលប៉ុណ្ណាទេ "*

*សមាជិកក្រុមប្រឹក្សាឃុំនៅស្រុកស្រះរាំង ខេត្តបន្ទាយមានជ័យ ក៏បានលើកឡើងថាៈ "កសិករកម្ពុជាមានជីវភាពក្រីក្រ ពីព្រោះគ្មានទឹកគ្រប់គ្រាន់សំរាប់ធ្វើស្រែ"*

សំដីខាងលើ បង្ហាញពីទិដ្ឋភាពសំខាន់មួយនៃបញ្ហាទឹកនៅក្នុងវិស័យកសិកម្ម ដែលប្រជាជនកម្ពុជាជាង ៨0% ត្រូវពឹងផ្អែកលើវាដោយផ្ទាល់ រឺដោយប្រយោល ។ ដោយដឹងពីតួនាទីដ៏សំខាន់នៃប្រព័ន្ធស្រោចស្រពសំរាប់ការអភិវឌ្ឍន៏ជាតិ រដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ជាពិសេសលើប្រព័ន្ធនេះ ពីព្រោះវាមានសក្តានុពលខ្លាំងក្លា ផ្តល់ផលប្រយោជន៏ដល់ប្រជាកសិករខ្មែរ ។ ប្រព័ន្ធស្រោចស្រពជួយឱ្យកសិករមិនសូវពឹងផ្អែកលើទឹកភ្លៀង និងញាំងឱ្យផលស្រូវវស្សាអាចទស្សទាយបានច្បាស់គួរសម ។ ទន្ទឹមគ្នានេះ កសិករអាចដាំដុះបាន ២-៣ដង ក្នុងមួយឆ្នាំ ។ ស្រូវអង្ករ ជាអាហារមូលដ្ឋានដ៏ចំបង ហើយជួនកាលក្លាយជា ដំណាំលក់យកប្រាក់ដែលជាប្រភពចំបង ផ្តល់ការងារឱ្យប្រជាជនកម្ពុជា ហើយកំណើននៅក្នុងវិស័យនេះមិនត្រឹមតែនាំឱ្យមានកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយធ្វើឱ្យប្រាក់ចំណូលបែងចែកបានល្អផង ។ លើសពីនេះ ប្រព័ន្ធស្រោចស្រព ជួយឱ្យកសិករអាចដាំដុះដំណាំលក់យកប្រាក់បានច្រើនប្រភេទ ដូចជា បន្លែ ឪឡឹក និង ពោត ជាដើម ។

ការកសាងប្រព័ន្ធស្រោចស្រពតែមួយមុខ មិនអាចគ្រប់គ្រាន់ទេ ហើយគេត្រូវពិនិត្យពីបញ្ហាពាក់ព័ន្ធនឹងអភិបាលកិច្ច ដើម្បីឱ្យប្រព័ន្ធស្រោចស្រពដំណើរការបានជោគជ័យ ។ អត្ថបទនេះ រាយការណ៍ពីការវិភាគខាងសង្គមកិច្ច លើការគ្រប់គ្រងធនធានទឹកនៅ ១៨ទំនប់ទឹក ក្នុងតំបន់បឹងទន្លេសាប ។ យោងតាមលទ្ធផលជាដំបូងនៃការសិក្សា អត្ថបទនឹងពិភាក្សាពីបញ្ហាការបែងចែកទឹក ការចូលរួមរបស់ប្រជាជន ដំណើរការ ការថែទាំជួសជុល និងការដោះស្រាយទំនាស់ ដែលអាចជះឥទ្ធិពលដល់អភិបាលកិច្ចទឹក ។

## ប្រវត្តិសហគមន៍កសិករប្រើប្រាស់ទឹក (FWUC)

តាមការប៉ាន់ស្មាន ៩0% នៃប្រព័ន្ធស្រោចស្រពកម្ពុជា បានកសាងឡើងនៅអំឡុងរបបប៉ុលពត ។ ក្នុងនេះ សំណង់ជាច្រើន មិនបានរចនារៀបចំល្អទេ ហើយក្រោយរបបប៉ុលពតដួលរលំនៅឆ្នាំ១៩៧៩ ក៏ត្រូវបោះបង់ចោលគ្មានដំណើរការអ្វីទាំងអស់ ធ្វើឱ្យផលិតកម្មស្រូវត្រូវពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង ។ ស្រែភាគច្រើនប្រើប្រាស់ទឹកភ្លៀង ហើយភ្លៀងតែងតែធ្លាក់មិនទៀងទាត់ទេ ។ បើសិនក្រមានភ្លៀងនៅដើមរដូវវស្សា ការដាំដុះនឹងត្រូវរអាក់រអួល រឺក៏ខូចអស់មួយរដូវពេញតែម្តង ។ ម្យ៉ាងទៀត មានកូនរដូវប្រាំងមួយនៅចំកណ្តាលរដូវវស្សា ដែលជាពេលស្រូវត្រូវការទឹកខ្លាំងបំផុត ហើយអាចខូចខាតទាំងអស់បាន ។

ដើម្បីសំរួលបញ្ហាផ្គត់ផ្គង់ទឹក និងសំរេចបានកំណើនកសិកម្ម រដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់លើប្រព័ន្ធស្រោចស្រព ដោយកសាងរចនាសម្ព័ន្ធ និងពង្រឹងប្រព័ន្ធគ្រប់គ្រង ។ ចាប់ពីឆ្នាំ១៩៩៣មក ការគ្រប់គ្រងធនធានទឹក បាននឹងកំពុងផ្ទេរពីប្រព័ន្ធគ្រប់គ្រងដោយថ្នាក់ជាតិ ទៅអាជ្ញាធរមូលដ្ឋាន ។ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ បានណែនាំឱ្យប្រើ "ការគ្រប់គ្រងដំណើរការអភិវឌ្ឍន៏ប្រព័ន្ធស្រោចស្រពដោយមានការចូលរួម (PIMD)" ដែលផ្តោតលើការចូលរួមរបស់ប្រជាជនមូលដ្ឋាន និងតំរូវឱ្យមានការសំរេចចិត្តនៅកំរិតទាបបំផុតដែលសមស្រប ដោយមានការពិគ្រោះយោបល់ជាមួយប្រជាជន និងការចូលរួមពីអ្នកប្រើប្រាស់ ក្នុងការធ្វើផែនការ និងអនុវត្តន៏គំរោង (Dublin Statement on Water and Sustainable Development) ។ គេបានអះអាងថា ការចូលរួមរបស់ប្រជាជនមូលដ្ឋានក្នុងការងារអភិវឌ្ឍន៏ អាចធ្វើឱ្យគំរោងមានការទទួលស្គាល់ជាលក្ខណៈនយោបាយ និងសង្គម (Schumacher 1973; McDonald and Kay 1988; Ojendal 2000) ពីព្រោះប្រជាជនអាចប្រាប់ពីតំរូវការ និងញាំងឱ្យការងារដើរស្របតាមផលប្រយោជន៏របស់ខ្លួន ។ ដូច្នេះ វាធ្វើឱ្យប្រជាជនមូលដ្ឋានកាន់តែចាប់អារម្មណ៏ថា ខ្លួនជាម្ចាស់លើគំរោង (Moote et al. 1997) ។ ចំណេះដឹងបច្ចេកទេសតាំងពីបុរាណរបស់ប្រជាជនមូលដ្ឋាន អាចមានតំលៃខ្លាំងណាស់សំរាប់ការគ្រប់គ្រងធនធានទឹក តាំងពី ការប្រមូលយកទឹក ការគ្រប់គ្រងអាងទឹក រឺប្រព័ន្ធស្រោចស្រព ។

PIMD នៅកម្ពុជា ជាសហគមន៏កសិករប្រើប្រាស់ទឹក (FWUC) ដែលបានបង្កើតឡើង ដើម្បីគ្រប់គ្រងប្រព័ន្ធស្រោចស្រពតាមបែបប្រជាធិបតេយ្យ ។ យោងតាមច្បាប់ជាធរមាន កសិករនៅក្នុងតំបន់ស្រោចស្រព (តំបន់ទទួលបានទឹកពីប្រព័ន្ធស្រោចស្រព) ត្រូវដាក់ពាក្យសុំចូលជាសមាជិក ដើម្បីអាចប្រើប្រាស់ទឹកពីទំនប់ស្តុកទឹក ដោយក្នុងនេះ កសិករត្រូវយល់ព្រមបង់វិភាគទានជាកំរៃសេវា ។ ម្យ៉ាងទៀត FWUC មានសិទ្ធិផាកពិន័យ រឺដាក់ទណ្ឌកម្មដល់អ្នកដែលមករំខាន រឺបំផ្លាញផលប្រយោជន៏របស់ FWUC រឺរបស់ពួកសមាជិកសហគមន៏ (MOWRAM, 2000) ។ ប៉ុន្តែគេមិនច្បាស់ទេថា FWUC អាចធ្វើការបានរលូនប៉ុណ្ណាជាមួយនឹង របៀបរបបដែលមានស្រាប់ យោងតាមក្រឹត្យក្រម ជំនឿ ធនធានសង្គម (ទំនុកចិត្ត និង បណ្តាញ) និងនយោបាយនៅក្នុងមូលដ្ឋាន ។ លោក Ojendal (2000) បានដាស់តឿនថា ការគ្រប់គ្រងធនធានមួយដែលធ្លាប់តែទទួលបានដោយឥតបង់ថ្លៃគឺ "យ៉ាប់

---

* លោក គីម ស៊ាន ស៊ូម៉ាត្រា និង កញ្ញា ខៀវ ដារាវី ជាអ្នកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI ។ អត្ថបទនេះ ផ្អែកលើការរកឃើញជាដំបូង១នៃកម្មវិធីអភិវឌ្ឍន៏សមត្ថភាពស្រាវជ្រាវគ្រប់គ្រងធនធានទឹក ។

បន្តិច" ហើយវាមិនច្បាស់ទេថា តើស្ថាប័នមូលដ្ឋាន ដូចជា សហគមន៍កសិករប្រើប្រាស់ទឹកជាដើម អាចមានបែបបទយ៉ាងណាក្នុងការគ្រប់គ្រងធនធានទឹក ដើម្បីឱ្យវាធានាបាននូវកំណើនសេដ្ឋកិច្ច សមធម៌ក្នុងសង្គម និងចីរភាពខាងហិរញ្ញវត្ថុ និងបរិស្ថាន ។

## លទ្ធផលរកឃើញ

### *ការបែងចែកទឹកនៅក្នុងប្រព័ន្ធស្រោចស្រពនីមួយៗ*

FWUC ត្រូវប្រឈមនឹងបញ្ហាធំៗជាច្រើនលើការបែងចែកទឹកក្នុងតំបន់ទំនប់ទឹកទៅឱ្យកសិករជាសមាជិក (តាមធម្មតា គឺកសិករធ្វើស្រែប្រាំង) ។ រដូវប្រាំងនៅកម្ពុជា មានរយៈពេលប្រហែល ៣ខែ ចាប់ពីខែធ្នូ ដល់ ខែមីនា ហើយជារឿយៗ គេពុំមានទឹកគ្រប់គ្រាន់សំរាប់ស្រោចស្រពរហូតដល់រដូវច្រូតកាត់ទេ ។ នៅពេលមើលឃើញដំណាំរបស់ខ្លួនអាចខូចខាត ដោយសារកង្វះទឹក កសិករចង់បញ្ចូលទឹកឱ្យបានច្រើនទៅក្នុងស្រែរបស់ខ្លួន មុនពេលស្ទឹងអូរវារីងអស់ ដូច្នេះហើយក៏មានការប្រកួតប្រជែងគ្នាយ៉ាងតឹងតែង ។ នៅឯទំនប់ទឹកត្រពាំងត្របែក នៅខេត្តកំពង់ឆ្នាំង ក្នុងកិច្ចប្រឹងប្រែងបែងចែកទឹកឱ្យបានស្មើភាពទៅឱ្យសមាជិកខ្លួន FWUC បានសុំជំនួយពីក្រុមប្រឹក្សាឃុំសង្កាត់ ដែលបានចេញលិខិតណែនាំកសិករ ឱ្យបែងចែកទឹកគ្នាប្រើប្រាស់ឱ្យបានស្មើៗគ្នា ។ ប៉ុន្តែកសិករ មិនយកចិត្តទុកដាក់ដល់ការរៀបចំនោះទាល់តែសោះ ហើយពោលថា: "យើងហូបបាយ មិនមែនហូបក្រដាសទេ" ។

តារាងពេលផ្គត់ផ្គង់ទឹក ក៏ជាបញ្ហាមួយធំដែរសំរាប់ FWUC ភាគច្រើន ។ នៅខេត្តបាត់ដំបង មានសហគមន៍កសិករប្រើប្រាស់ទឹកមួយ បានផ្អែកលើបទពិសោធន៍កន្លងមក ច្នៃចេញជាបែបបទមួយ ដែលពួកគេគិតថាអាចជួយឱ្យពួកគេបែងចែកទឹកបានល្អ ។ តាមបែបបទនោះ នៅពេលគេបើកទ្វារទឹកធំ ហើយមានទឹកក្នុងប្រឡាយមេ កសិករនៅខ្សែទឹកខាងក្រោម អាចប្រើប្រាស់ទឹកធ្វើស្រែបានមុន រហូតដល់ស្រូវធំធាត់លែងត្រូវការទឹក ។ បន្ទាប់មក កសិករនៅខ្សែទឹកខាងលើ អាចចាប់ផ្តើមដាំដុះបាន ។ ប៉ុន្តែផែនការនេះបានទទួលបរាជ័យ ។ កសិករមិនយកចិត្តទុកដាក់នឹងបែបបទនេះទេ ហើយអ្នកនៅខ្សែទឹកខាងលើបានកសាងទំនប់បណ្តោះអាសន្នកាត់ប្រឡាយមេ ដើម្បីបង្វែរទឹកចូលទៅក្នុងស្រែពួកគេ នៅពេលទ្វារទឹកបើក ។ សហគមន៍កសិករប្រើប្រាស់ទឹកមិនអាចធ្វើអ្វីកើតទេ បានត្រឹមតែឈរមើលប៉ុណ្ណោះ ។

### *ការបែងចែកទឹកពីប្រព័ន្ធស្រោចស្រពមួយ ទៅប្រព័ន្ធស្រោចស្រពមួយទៀត*

បញ្ហាប្រឈមមួយទៀតរបស់ FWUC គឺជាការផ្ទេរទឹកពីប្រព័ន្ធស្រោចស្រពមួយទៅកាន់ប្រព័ន្ធមួយទៀត នៅក្នុងដែនរងទឹកភ្លៀងតែមួយ ដោយសារភាពមិនស៊ីគ្នារវាងចំណុះដែនរងទឹកភ្លៀង នឹងតំរូវការទឹក ។ ទំនប់ទឹកកសាងនៅទសវត្សរ៍១៩៨០ និង ១៩៩០ ត្រូវបានរចនារៀបចំ ផ្តល់មូលនិធិ និងកសាងឡើង ដោយទីភ្នាក់ងារផ្សេងៗ ដូចជា អង្គការ AFSC និង កម្មវិធីប្រាសាក់ ជាដើម ។ ឧ. នៅស្ទឹងជ្រៃបាក់ ខេត្តកំពង់ឆ្នាំង ពុំមានការសិក្សាលំអិតពីដែនរងទឹកភ្លៀងនានា នៅមុនពេលរចនារៀបចំប្រព័ន្ធស្រោចស្រពនីមួយៗទេ ពីព្រោះនៅទសវត្សរ៍១៩៨០ និង១៩៩០ ខ្មែរក្រហមនៅកាន់កាប់ទឹកដីជាច្រើននៅឡើយ ហើយមានការប្រយុទ្ធគ្នាជារឿយៗនៅតាមកន្លែងទាំងនោះ ។ ក្នុងករណីភាគច្រើន ប្រព័ន្ធស្រោចស្រពបានកសាងឡើងជាសំខាន់ ដើម្បីផ្គត់ផ្គង់ទឹកបន្ថែមជាបន្ទាន់ដល់ស្រូវវស្សា និងធ្វើការគ្រប់គ្រងទឹកជំនន់ ។ ដោយសារហេតុផលខាងសន្តិសុខ ប្រព័ន្ធទាំងនោះត្រូវបានកសាងនៅតំបន់ខ្សែទឹកខាងក្រោមនៃដែនរងទឹកភ្លៀង នៅត្រង់កន្លែងមានសុវត្ថិភាព ។ បន្ទាប់ពីមានសន្តិសុខ និងស្ថិរភាពក្នុងប្រទេស សកម្មភាពអភិវឌ្ឍន៍ និងប្រព័ន្ធស្រោចស្រព ក៏កើនឡើងដែរ ។ នៅតំបន់ខ្សែទឹកខាងលើ មានការកសាងប្រព័ន្ធស្រោចស្រពថែមទៀត ដែលជួយឱ្យកសិកររស់នៅទីនោះអាចយកទឹកមកប្រើប្រាស់បាន ។ ប៉ុន្តែទំនប់ទឹកនៅតំបន់ខ្សែទឹកខាងលើ បានកាត់បន្ថយបរិមាណទឹកសំរាប់អ្នកនៅខ្សែទឹកខាងក្រោម ហើយនៅពេលមានទំនប់កាន់តែច្រើននៅតំបន់ខ្សែទឹកខាងលើ បរិមាណទឹកក៏កាន់តែថយចុះសំរាប់ប្រជាជននៅខ្សែទឹកខាងក្រោម ។

ទន្ទឹមនឹងការប្រកួតប្រជែងរវាងប្រព័ន្ធស្រោចស្រពនីមួយៗ ដើម្បីយកទឹកបន្ថែម កំណើនការធ្វើស្រែប្រាំងដោយសារមានទឹកស្រោចស្រព បាននាំឱ្យមានការប្រកួតប្រជែងគ្នា នៅក្នុងប្រព័ន្ធស្រោចស្រពតែមួយ និងរវាងប្រព័ន្ធនានា ។ ជាគោលការណ៍ គឺមានផ្ទៃដីមួយចំនួនច្បាស់លាស់ដែលមានការព្រមព្រៀងគ្នាថា អាចទទួលបានទឹកពីប្រព័ន្ធស្រោចស្រពនៅរដូវប្រាំង ។ ប៉ុន្តែ ក្នុងការអនុវត្តន៍ជាក់ស្តែង គេពិបាកនឹងកំណត់បរិមាណដាំដុះនៅក្នុងតំបន់នោះណាស់ ។

បញ្ហាប្រឈមមួយទៀតទាក់ទិននឹងការបែងចែកទឹក រវាងប្រព័ន្ធស្រោចស្រពនានា គឺការសំរបសំរួល និងកិច្ចសហការមិនល្អរវាង FWUC ។ ផ្លូវទឹកឆ្លងកាត់ខេត្ត ស្រុក ឃុំ និងភូមិខុសៗគ្នា ដែលមានសហគមន៍កសិករប្រើប្រាស់ទឹកខុសៗគ្នា ។ ជារឿយៗ សហគមន៍កសិករប្រើប្រាស់ទឹកមិនអាចផ្លាស់ប្តូរព័ត៌មានពីអ្វី ដែលកើតមាននៅតំបន់នីមួយៗទេ ហើយពួកគេធ្វើសេចក្តីសំរេចចិត្តដោយឯករាជ្យ គ្មានការចូលរួមពីសហគមន៍កសិករប្រើប្រាស់ទឹកឯទៀតឡើយ ។ ជារឿយៗការសំរេចចិត្តរបស់សហគមន៍កសិករប្រើប្រាស់ទឹកនៅខ្សែទឹកខាងលើ វាជះឥទ្ធិពលយ៉ាងខ្លាំងដល់សហគមន៍កសិករប្រើប្រាស់ទឹកនៅខ្សែទឹកខាងក្រោម ។ ឧ. ពេលខ្លះ សហគមន៍កសិករប្រើប្រាស់ទឹកនៅខ្សែទឹកខាងលើបានទប់យកទឹកទាំងអស់ទៅប្រើប្រាស់ ធ្វើឱ្យអ្នកនៅខ្សែទឹកខាងក្រោម ខ្វះទឹកនៅចំពេលដែលស្រូវត្រូវការទឹកខ្លាំងបំផុត ហើយពេលខ្លះទៀត អ្នកខាងលើបានបើកបញ្ចេញទឹកទាំងអស់ធ្វើឱ្យលិចលង់ តំបន់ខ្សែទឹកខាងក្រោមនៅចំពេលច្រូតកាត់តែម្តង ។ ដំណើរការ ប្រព័ន្ធស្រោចស្រពទឹកនីមួយៗ វាជាប់ទាក់ទងគ្នាចុះឡើង ។ ហេតុនេះ កិច្ចសហការជិតស្និទ្ធរវាងប្រព័ន្ធនានាក្នុងដែនរងទឹកភ្លៀងតែមួយ គឺសំខាន់ខ្លាំងណាស់ ។ សហគមន៍កសិករប្រើប្រាស់ទឹក មានការទទួលខុសត្រូវលើប្រព័ន្ធនៅតាមតំបន់ខុសៗគ្នាក៏ពិតមែន ប៉ុន្តែត្រូវមានការប្រាស័យទាក់ទងគ្នាទៅវិញទៅមកជាប្រចាំ ដើម្បីបង្កើតជាផែនការមេសំរាប់ការប្រើប្រាស់ទឹក ។

### *ការចូលរួម*

យោងតាមឯកសារជាច្រើន ជោគជ័យនៃការគ្រប់គ្រងទឹកនៅមូលដ្ឋាន វាអាស្រ័យលើការចូលរួមរបស់ប្រជាជន ដែលអាចផ្តល់ជាចំណេះដឹងខាងផ្នែកបច្ចេកទេសជាក់ស្តែង ហើយសំខាន់ជាងនេះ គឺពួកគេមានអារម្មណ៍ក្លាយជាម្ចាស់ ។ ប៉ុន្តែការព្យាយាមឱ្យពួកគេចូលរួមក្នុងការគ្រប់គ្រង រឺប្រើប្រាស់ទឹកឱ្យមានប្រយោជន៍ វាក៏ពិបាកដូចគ្នានឹងការបែងចែកទឹកនៅពេលក្រទឹកដូច្នោះដែរ ។

FWUC បានជួបបញ្ហាធំក្នុងការកៀងគរឱ្យប្រជាជនមកចូលរួម ។ នៅតំបន់ខ្លះ ក្រោយពេលប្រព័ន្ធស្រោចស្រពបានកសាងនិងស្តាររួចរាល់ហើយ គេមានទឹកច្រើនណាស់ ប៉ុន្តែកសិករមិនបានប្រើប្រាស់វាជាប្រយោជន៍ទេ ។ នៅតំបន់ខ្លះ FWUC បានព្យាយាមឱ្យប្រជាជនមូលដ្ឋានចូលរួម ប៉ុន្តែត្រូវប្រឈមមុខនឹងប្រពៃណីជាយូរលង់របស់កសិករ ។ តាមទំលាប់ កសិករធ្វើ

ស្រែវស្សាតាមសំរួលខ្លាំងណាស់ ។ FWUC នៅខេត្តកំពង់ធំបានលើកថា ក្នុងការធ្វើស្រែវស្សា កសិករគ្រាន់តែភ្ជួររាស់ដី និងសាបព្រួស ហើយគ្មានធ្វើអ្វីទៀតទេ រហូតដល់ពេលច្រូតកាត់ ។ ប៉ុន្តែស្រែប្រាំងទាមទារឱ្យកសិករចំនាយពេលច្រើនណាស់នៅឯស្រែ ដើម្បីត្រួតពិនិត្យទឹក ការពារកុំឱ្យសត្វចូលស៊ីស្រូវ ពីព្រោះជាទំលាប់ពួកគេព្រលែងពួកវានៅរដូវប្រាំង ។ ម្យ៉ាងទៀត កសិករត្រូវចំណាយច្រើនជាងមុន ដោយពួកគេត្រូវបង់កំរៃប្រើប្រាស់ទឹក (ទឹកនៅរដូវវស្សា គ្មានបង់ប្រាក់អ្វីទេ) ហើយស្រូវប្រាំងក៏ត្រូវការជីច្រើនជាងដែរ ។

ថ្វីបើមានការងារលើសមុន និងត្រូវចំណាយច្រើន ប៉ុន្តែមិនច្បាស់ថាបានផលនោះទេ ពីព្រោះកសិករអាចជួបនឹងគ្រោះសត្វចង្រៃបំផ្លាញដំណាំ ។ នៅរដូវវស្សា ដីស្ទើរតែទាំងអស់មានការដាំដុះ ដូច្នេះការខូចខាត ដោយសារសត្វចង្រៃ វាមានតិចជាង ។ ស្រូវប្រាំងគ្របដណ្តប់ផ្ទៃដីតូចជាង ដូច្នេះសត្វចង្រៃអាចបំផ្លិចបំផ្លាញធ្ងន់ជាង ពីព្រោះសត្វចង្រៃមានច្រើនជាងក្នុងដីស្រែមួយហិកតា១ ។ មន្ត្រីផ្សព្វផ្សាយកសិកម្មនៅខេត្តពោធិ៍សាត់ បានពោលថា "ធ្វើស្រែប្រាំង គឺដូចជាបើកភោជនីយដ្ឋានបំរើសត្វកណ្តុរអញ្ចឹង" ។

នៅតំបន់ខ្លះ ដូចជាខេត្តពោធិ៍សាត់ និង សៀមរាប កសិករមិនប្រើប្រាស់ប្រព័ន្ធស្រោចស្រពទេ ដោយសារភាពក្រីក្រខ្លាំងពេក ។ កសិករមួយចំនួនមិនអាចទទួលផលពីប្រព័ន្ធនេះបាន ពីព្រោះគាត់មិនធ្វើស្រូវប្រាំង ហើយបែរជាទៅធ្វើពលករនៅឯទីក្រុង រកអុស រឺជីកយកថ្មម៉ាប ដែលជាការងារអាចរកប្រាក់បានភ្លាម១ ។ គេអាចសង្កេតឃើញពីផលប៉ះពាល់នៃភាពក្រីក្រ តាមរយៈអ្នកក្រលក់ដីក្នុងតំលៃខ្ពស់ ទៅទិញដីមួយឡូតិ៍ផ្សេងទៀតដែលថោកជាង ប៉ុន្តែនៅឆ្ងាយពីប្រព័ន្ធស្រោចស្រព ។

ទោះបីដោយសារទំនៀមទំលាប់ រឺភាពក្រីក្រតោកយ៉ាកក្តី ប៉ុន្តែរឿងដែលប្រជាជនមិនប្រើប្រាស់ប្រព័ន្ធស្រោចស្រព រឺបង់ថ្លៃទឹក បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការងារជាទូទៅ និងជោគជ័យនៃ FWUC ។ FWUC ពឹងផ្អែកយ៉ាងខ្លាំងលើប្រាក់វិភាគទានរបស់សមាជិក ។ មាត្រា២៤ នៃច្បាប់ FWUC តំរូវឱ្យកសិករដែលទទួលផលពីប្រព័ន្ធស្រេចស្រព បង់ថ្លៃប្រើប្រាស់ទឹក ។ ប៉ុន្តែជាប្រវត្តិសាស្ត្រ កសិករកម្ពុជាធ្វើស្រែពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង និងមិនដែលបង់ថ្លៃទឹកទេ ដូច្នេះគំនិតចង់ឱ្យកសិករបង់ថ្លៃប្រើប្រាស់ទឹក គឺជាបញ្ហារសើប ហើយពួកអ្នកនយោបាយបានធ្វើឱ្យវាកាន់តែធ្ងន់ធ្ងរថែម ។ អ្នកដឹកនាំគណៈបក្សនៅមូលដ្ឋាន បានប្រើប្រាស់ប្រព័ន្ធស្រោចស្រពជាឧបករណ៍ឃោសនាឱ្យគណៈបក្ស ដោយប្រាប់ប្រជាជនថា មិនបាច់បង់ថ្លៃអ្វីទេ ពីព្រោះរដ្ឋត្រូវកសាងទំនប់ទឹកសំរាប់ឱ្យប្រជាជនប្រើប្រាស់ ។ ទិដ្ឋភាពខាងនយោបាយមួយទៀត គឺមុនពេលបោះឆ្នោត គណៈបក្សនយោបាយសុំឱ្យប្រជាជនបោះឆ្នោតឱ្យខ្លួនដោយសន្យាថាលែងយកថ្លៃប្រើប្រាស់ទឹក ។ តើការប្រមូលទារថ្លៃទឹកជះឥទ្ធិពលយ៉ាងណាចំពោះការបំពេញតួនាទី និងចីរភាពរបស់សហគមន៍កសិករប្រើប្រាស់ទឹក?

## *ប្រតិបត្តិការ*

កំហុសបច្ចេកទេសក្នុងការរចនារៀបចំទំនប់ទឹក វាចោទបញ្ហាយ៉ាងធំដល់ការថែទាំជួសជុល និងប្រតិបត្តិការរបស់ FWUC ។ ឧ. នៅទំនប់ត្រពាំងថ្ម ខេត្តបន្ទាយមានជ័យ មានទ្វារទឹកធំដែលប្រើផ្ទាំងឈើបិទបើកទឹក ។ កសិករអាចកែតំរូវលំហូរទឹកចូលស្រែបាន ដោយដាក់ថែម រឺដកចេញផ្ទាំងឈើដោយដៃ ។ ប៉ុន្តែ នៅពេលជួសជុលលើកក្រោយនេះ គេបានផ្លាស់ប្តូរទ្វារ ទៅជាទ្វារស្វ័យប្រវត្តិវិញ ។ ទ្វារនេះអាចកែតំរូវលំហូរទឹកដោយខ្លួនឯង ដើម្បីកាត់បន្ថយការងាររបស់ FWUC ប៉ុន្តែវាដំណើរការមិនត្រឹមត្រូវទេ ។ បើតាម FWUC នៅមូលដ្ឋាន ទ្វារនឹងបើកនៅពេលមានទឹកច្រើនក្នុងទំនប់ ប៉ុន្តែវាមិនអាចបិទដើម្បីទប់ទឹកទុក ទៅតាមកំរិតដែលគេចង់បាននោះទេ ។ ទ្វារថ្មីនេះច្រើនបើកបង្ហូរទឹកចេញអស់រលីង ធ្វើឱ្យជន់លិចដីស្រែនៅខ្សែទឹកខាងក្រោម ។

លក្ខខណ្ឌរូបវន្តបានកាត់បន្ថយលទ្ធភាពរបស់ FWUC ក្នុងការផ្គត់ផ្គង់ទឹកឱ្យបានគ្រប់គ្រាន់ដល់កសិករ ។ ប្រព័ន្ធស្រោចស្រពភាគច្រើន ពុំមានលក្ខណៈពេញលេញទេ ។ ឧ. ទំនប់ត្រពាំងថ្ម មានតែអាងស្តុកទឹកប៉ុណ្ណោះ រីឯប្រឡាយមេវាខូចខាតយ៉ាងខ្លាំង និងគ្មានកូនប្រឡាយចែកចាយទឹកទេ ។ ម្យ៉ាងទៀត ប្រឡាយមេដែលនាំទឹកទៅប្រព័ន្ធស្រោចស្រពស្រះរាំង នៅបន្ទាយមានជ័យ ក៏ខូចខាតខ្លាំងដែរ ។ យោងតាមប្រធាន FWUC នៅទីនោះ ប្រឡាយមេ បានខូចនៅ ១៣កន្លែងខុស១គ្នា ដោយសារទឹកជំនន់កាលពីមួយឆ្នាំមុន ។ ស្ថានភាពប្រឡាយមិនសូវល្អនេះ នាំឱ្យ FWUC មិនអាចបំពេញតំរូវការកសិករបានទាន់ពេល ។ កសិករម្នាក់លើកថា "កាលពីឆ្នាំមុន ខ្ញុំសុំទឹកពី FWUC នៅខែវិច្ឆិកា ហើយពួកគេបានទៅចរចាជាមួយឃុំនៅខ្សែទឹកខាងលើ ដើម្បីឱ្យគេបើកទឹកបង្ហូរមក ។ ក្នុងពេលជាមួយគ្នា ខ្ញុំក៏ចាប់ផ្តើមភ្ជួររាស់ដាំដុះ និងរង់ចាំទឹក ។ យើងចាំហើយចាំទៀត ។ មួយខែក្រោយពេលខ្ញុំសាប ទឹកក៏ហូរមកដល់ ប៉ុន្តែវាយឺតពេលទៅហើយ ពីព្រោះស្រូវបានងាប់អស់រលីង ។

ធនធានតិច ក៏ជាឧបសគ្គក្នុងការគ្រប់គ្រងទឹកដែរ ។ ប្រភពចំណូលរំពឹងទុករបស់ FWUC គឺថវិកាបានមកពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ថ្លៃទឹកស្រោចស្រព និងសកម្មភាពអាជីវកម្មរបស់ FWUC ផ្ទាល់ ។ ប៉ុន្តែចំណូលពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល់ និងសកម្មភាពអាជីវកម្ម មានតិចតួចបំផុត រឺគ្មានសោះ ហើយ FWUC ស្ទើរតែមិនអាចប្រមូលថ្លៃប្រើប្រាស់ទឹកបានទៀត ។ ដោយសារចំណូលតិចតួច ដូច្នេះ FWUC មិនបានបំពេញតួនាទីខ្លួនប្រកបដោយប្រសិទ្ធភាពទេ ពីព្រោះគណៈកម្មាធិការទទួលបានកំរៃតែ ១០០០០រៀល-២០០០០រៀលប៉ុណ្ណោះ ក្នុង១ឆ្នាំ គឺមិនគ្រប់ទិញសាំងធ្វើដំណើរមួយជើងទៅចរចារជាមួយឃុំនៅខ្សែទឹកខាងលើផង ហើយពួកគេត្រូវប្រើប្រាស់មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនតែរាល់១លើក ។

ម្យ៉ាងទៀត កសិករមិនបានជួយសំរួលដល់ការងារគណៈកម្មាធិការទេ ។ យោងតាមការបកស្រាយខាងលើ បរិមាណទឹកនៅក្នុងប្រព័ន្ធស្រោចស្រព ទោះតិចក្តី ច្រើនក្តី គឺកំណត់ដោយអ្នកនៅខ្សែទឹកខាងលើ ប៉ុន្តែកសិករបន្ទោសតែ FWUC ក្នុងមូលដ្ឋានខ្លួនប៉ុណ្ណោះ ។ សមាជិកគណៈកម្មាធិការម្នាក់ប្រាប់ថា "នៅក្នុងមួយរដូវច្រូតកាត់ យើងត្រូវគេជេរបីដង ។ លើកទី១ នៅពេលខ្វះទឹកនាំឱ្យផលដំណាំខូច ។ លើកទី២ នៅពេលទឹកជន់ពីខ្សែទឹកខាងលើ ហើយបំផ្លាញដំណាំ និងលើកទី៣ នៅពេលយើងទៅប្រមូលថ្លៃប្រើប្រាស់ទឹក" ។

បញ្ហាខាងលើ បានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ចីរភាពរបស់គណៈកម្មាធិការ FWUC ដូចក្នុងសំដីរបស់សមាជិកគណៈកម្មាធិការម្នាក់ នៅខេត្តកំពង់ឆ្នាំងដែលថា "ប្រហែលជាយើងគួរឈប់ហើយ ពីព្រោះយើងមិនបានទទួលប្រាក់កំរៃសំរាប់សេវារបស់យើងទេ គឺមានតែគេបន្ទោស" ។ ឧ. FWUC នៅទំនប់ថ្មល់ដាច់ ខេត្តបន្ទាយមានជ័យ ធ្លាប់មានសមាជិកគណៈកម្មាធិការ ៥នាក់ ប៉ុន្តែឥឡូវនៅសល់តែ ៣នាក់ទេ ។ រឿងនេះក៏កើតឡើងចំពោះ FWUC នៅទំនប់កំពឹងពួយ (បាត់ដំបង) ទំនប់កំប៉ាង (ពោធិ៍សាត់) ទំនប់មេទឹក (ពោធិ៍សាត់) ទំនប់តាំងក្រសាំង (កំពង់ឆ្នាំង) ដែរ ។ ប្រធាន FWUC នៅតាំងក្រសាំង ពោលថា "កាលពីមុន សមាជិកគណៈកម្មាធិការសប្បាយរីករាយចំពោះការគ្រប់គ្រងប្រព័ន្ធស្រោចស្រព ប៉ុន្តែឥឡូវនេះ ម្នាក់១បាក់ទឹកចិត្ត ពីព្រោះមិនបានទទួលកំរៃអ្វីសោះ" ។

*ការថែទាំជួសជុល*

FWUC ក៏ខ្វះធនធានសំរាប់ថែទាំជួសជុលប្រព័ន្ធស្រោចស្រពដែរ ។ ប្រព័ន្ធងាយខូចខាត ដោយសារការហូរច្រោះ ទឹកជំនន់ សត្វពាហនៈបំផ្លាញ និងចោរលួច ដូចជា របាំដែក និងទ្វារឈើ ជាដើម ។ ជាញឹកញយ ចំណាយជួសជុលខ្ពស់ជាងថវិការបស់ FWUC ដែលបានចំណូលពីថ្លៃប្រើប្រាស់ទឹក ដែលពិបាកប្រមូលបានជាខ្លាំង រឺប្រមូលមិនបានតែម្ដង ។

ការពិបាកបំផុត គឺជួនកាល សហគមន៍កសិករប្រើប្រាស់ទឹកត្រូវទៅជួសជុលប្រព័ន្ធស្រោចស្រពនៅតំបន់គេផ្សេង ។ ឧ. សហគមន៍កសិករប្រើប្រាស់ទឹកនៅស្រះរាំងត្រូវ ទទួលបន្ទុកថែទាំជួលជុល ប្រព័ន្ធនៅឯខ្សែទឹកខាងលើនៅពោធិ៍ពីរដើម (បន្ទាយមានជ័យ) ។ ប្រឡាយមេដែលនាំទឹកទៅស្រះរាំងត្រូវឆ្លងកាត់ពោធិ៍ពីរដើម ហើយវាបានខូចខាតជាច្រើនកន្លែង ប៉ុន្តែកសិករនៅទីនោះមិនធ្វើស្រែប្រាំង ដូច្នេះគេមិនចាប់អារម្មណ៍ជួសជុលប្រឡាយមេទេ ដោយទុកឱ្យសហគមន៍កសិករប្រើប្រាស់ទឹកនៅស្រះរាំង ទទួលខុសត្រូវលើរឿងនេះ ។

សហគមន៍កសិករប្រើប្រាស់ទឹកមួយចំនួន បានព្យាយាមដាក់បញ្ចូលការកសាងប្រព័ន្ធស្រោចស្រព ទៅក្នុងផែនការរបស់ក្រុមប្រឹក្សាឃុំ ប៉ុន្តែបទពិសោធន៍ជាក់ស្ដែងបង្ហាញថា លទ្ធភាពធ្វើដូច្នេះបានវាមានកំរិតតិចតួចណាស់ ។ សមាជិកម្នាក់នៃសហគមន៍កសិករប្រើប្រាស់ទឹកនៅខេត្តកំពង់ឆ្នាំងបញ្ជាក់ថា "យើងបានព្យាយាមបញ្ចូលប្រព័ន្ធស្រោចស្រពនេះ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំដែរ ប៉ុន្តែប្រព័ន្ធនេះមិនអាចយកឈ្នះទៅលើផ្លូវថ្នល់បានទេ" ។

*ទំនាស់ និងការដោះស្រាយ*

ឯកសារស្ដីពីការដោះស្រាយទំនាស់ក្នុងការគ្រប់គ្រងទឹកនៅកម្ពុជាមានតិចតួចណាស់ ប៉ុន្តែបទពិសោធន៍អន្តរជាតិ បង្ហាញថា ទំនាស់រវាងអ្នកប្រើប្រាស់ទឹកបានកើនឡើង ដោយសារការធ្វើវិមជ្ឈការ (UNDP 2006) ។ ទំនាស់នៅមូលដ្ឋានភាគច្រើន ពាក់ព័ន្ធនឹងការបែងចែកទឹករវាងប្រព័ន្ធស្រោចស្រពនានា ហើយវាតែងកើតឡើងពីចុងខែកុម្ភៈ ដល់ដើមខែមីនា នៅពេលកសិករត្រូវការទឹកធ្វើស្រែប្រាំង ។ ឧ. នៅឆ្នាំ២០០៦ ស្រូវប្រាំងនៅត្រពាំងត្របែក ខេត្តកំពង់ឆ្នាំង បានដុះលូតលាស់ល្អណាស់ រហូតដល់ពេលខ្វះទឹកនៅចុងខែកុម្ភៈ ។ ដោយមានព័ត៌មានតិចតួចពីរបបលំហូរទឹក កសិករក្នុងតំបន់នោះយល់ថា កង្វះទឹកបណ្ដាលមកពី FWUC និងកសិករនៅខ្សែទឹកខាងលើ មានចិត្តច្រណែននឹងជីវភាពធូរធារដោយសារផលស្រូវប្រាំងរបស់ពួកគេ ។ កសិករនៅខ្សែទឹកខាងក្រោមនិយាយថា "ដូច្នេះពួកគេក៏បិទទឹកទាំងអស់ មិនឱ្យហូរចុះមកតំបន់ខ្សែទឹកខាងក្រោម" ។

ទោះយ៉ាងនេះក្ដី សព្វថ្ងៃមិនទាន់មានក្របខ័ណ្ឌច្បាប់ច្បាស់លាស់ទេ (Sakhon and Lyda 1996) សំរាប់ដោះស្រាយទំនាស់ ហើយក្នុងករណីភាគច្រើន កសិករ និងសហគមន៍កសិករប្រើប្រាស់ទឹកបានប្រើប្រាស់វិធីសាស្ត្រផ្ទាល់ខ្លួន ដើម្បីដោះស្រាយបញ្ហា ។ ឧ. នៅពេលឃើញដំណាំស្រូវអាចខូចខាត កសិករបានរំលុយឱ្យសហគមន៍កសិករប្រើប្រាស់ទឹក ធ្វើដំណើរទៅតាំងក្រសាំងដើម្បីចរចាឱ្យគេបើកទឹក ។ តាមធម្មតា ការចរចាធ្វើឡើងជាលក្ខណៈក្រៅផ្លូវការប៉ុណ្ណោះ ។ បើសហគមន៍កសិករប្រើប្រាស់ទឹកត្រូវការទឹក ពួកគេយកម្ហូបអាហារ និងស្រា ទៅជាមួយដើម្បីធ្វើការចរចាជាមួយនឹងភាគីម្ខាងទៀត ។

ការបើកទឹកបង្ហូរពីតំបន់ខ្សែទឹកខាងលើ ជារឿយៗមិនប្រាកដថាមានទឹកមកដល់ប្រព័ន្ធស្រោចស្រពនៅខ្សែទឹកខាងក្រោមទេ ។ ប្រជាជនតែងគិតថា នៅពេលទឹកហូរមកដល់តំបន់ពួកគេ វាជារបស់ពួកគេ ដូច្នេះ ពួកគេមានសិទ្ធិធ្វើអ្វីក៏បានតាមចិត្តចង់ ។ នៅខេត្តកំពង់ធំ កំពង់ឆ្នាំង និង បន្ទាយមានជ័យ កសិករបានកសាងទំនប់បណ្ដោះអាសន្នបង្វែរទឹកចូលស្រែរបស់ខ្លួន ធ្វើឱ្យរអាក់រអួលដល់របៀបរបបអភិបាលកិច្ចធនធានទឹក ។ ប៉ុន្តែ FWUC មិនអាចបញ្ជាឱ្យពួកគេ យកទំនប់ចេញបានទេ ។

## ៣. សេចក្ដីសន្និដ្ឋាន

បញ្ហាដែលសហគមន៍កសិករប្រើប្រាស់ទឹកកំពុងប្រឈមមុខក្នុងការគ្រប់គ្រងទឹក បានកកើតឡើងតាំងពីដំណាក់កាលរចនារៀបចំប្រព័ន្ធស្រោចស្រព ហើយវាបំផុសសំណួរថា តើការគ្រប់គ្រង និងអភិបាលកិច្ចប្រព័ន្ធស្រោចស្រពអាចដោះស្រាយតាំងពីដំបូងៗបានរឺទេ ។ ស្របគ្នានេះដែរ ក៏គួរចោទសួរពីបញ្ហាជាទូទៅទាក់ទងនឹងសេដ្ឋកិច្ចនយោបាយនៃប្រព័ន្ធស្រោចស្រពដែរ ។ តើហេតុអ្វីបានជាគេកសាងគំរោងនៅទីតាំងសព្វថ្ងៃនេះ? ហេតុអ្វីកសិករមិនគោរពភាពពេញច្បាប់នៃសហគមន៍កសិករប្រើប្រាស់ទឹក? តើសហគមន៍កសិករប្រើប្រាស់ទឹក ពិតជាស្ថាប័នគ្រប់គ្រងធនធានទឹកនៅមូលដ្ឋានដែលមានច្បាប់ទ្រទ្រង់ត្រឹមត្រូវ រឺក៏គ្រាន់តែជាស្ថាប័នសាកល្បងដំបូងមួយប៉ុណ្ណោះ? តើហេតុអ្វីបានជាខ្វះកិច្ចសហការ និងសហប្រតិបត្តិការរវាងសហគមន៍កសិករប្រើប្រាស់ទឹកនានា ហើយតើត្រូវធ្វើយ៉ាងទើបមានកិច្ចសហការគ្នា? នៅពេលបញ្ហាទាំងនេះ ដោះស្រាយបានរួចរាល់ហើយ ទើបអាចនិយាយបានពី ការគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធភាពដោយសហគមន៍កសិករប្រើប្រាស់ទឹក ។

## ឯកសារយោង


International Conference on Water and the Environment (ICWE) (1992), "The Dublin Statement on Water and Sustainable Development", httpp://www.gdrc.org/uem/water/dublin-statement.html

McDonald, A.T. & D. Kay (1988), *Water resources—issues and strategies* (London: Longman)

Ministry of Water Resources and Meteorology (2000), "Circular No. 1 on the Implementation policy for sustainable irrigation systems" (Phnom Penh)

Moote, M.A., M. P. McClaran & Donna K. Chickering (1997), "Theory in practice: applying participatory democracy theory to public land planning", *Environmental Management,* 21: 6

Ojendal, J. (2000). "Sharing the good: Modes of managing water resources in the lower Mekong River Basin", PhD dissertation (Goteborg University)

Royal Government of Cambodia (2006), *National Development Strategic Plan 2006–2010* (Phnom Penh)

Sakhon, V. & P. Lyda (1996), "National institution for integrated water resource management", *CNMC and UNDDSMS* (Phnom Penh)

Schumacher, E. F. (1973), *Small is beautiful: A study of economics as if people mattered* (London: Bland and Briggs)

UNDP (2006), *Human development report: Beyond scarcity: Power, poverty and the global water crisis* (UNDP)